សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ឥទ្ធិបាទធម៌

www.hoksavann.org

ថ្ងៃទី៣១ ឧសភា ២០១២



«ឥទ្ធិបាទធម៌» ប្រែថា ធម៌ជាជើងទ្រឲ្យសំរេចកិច្ចការល្អគ្រប់យ៉ាង ដែលគេបានធ្វើ ។ បានសេចក្តីថា ដើម្បីឲ្យបានសំរេចកិច្ចការណាមួយ គេត្រូវតែអនុវត្តឥទ្ធិបាទធម៌នេះ ។ ឥទ្ធិបាទធម៌នេះមាន៤ប្រការគឺ ៖ ឆន្ទៈ, វិរិយៈ, ចិត្តៈ និង វិមំសា ។

១- ឆន្ទៈ ៖ ប្រែថាបំណាង គឺបំណាងដើម្បីធ្វើកិច្ចការណាមួយ ជាការគិតនៅក្នុងចិត្ត ដូចបំណាងសិក្សារៀនសូត្រ, បំណាងធ្វើការរកស៊ី, បំណាងឲ្យប្រទេសរបស់ខ្លួនបានសុខសន្តិភាពនិងរីកចំរើនលូតលាស់, បំណាងឲ្យព្រះពុទ្ធសាសនាគង់វង់ស្ថិតស្ថេរជាដើម ។ បំណាងនេះបានផ្តួចផ្តើមឡើងជាដំបូង មុននឹងចាប់ផ្តើមបំពេញការងារអ្វីមួយ ។ បំណាងនេះមាននៅក្នុងចិត្តគំនិត គឺជាការគូសវាសផែនការនៅក្នុងចិត្ត ។ ចំពោះឆន្ទៈឬបំណាងនេះ ព្រះពុទ្ធសាសនានិយាយតែផ្នែកកុសល មិននិយាយផ្នែកអកុសលឬអំពើបាប ដូចជាបៀតបៀនអ្នកដទៃឡើយ ។ បំណាងល្អ បំណាងត្រឹមត្រូវសំរាប់បំរើយុត្តិធម៌ បំរើសិទ្ធិសេរីភាព បំណាងឲ្យសង្គមមនុស្សបានសុខសន្តិភាពនិងចំរើនលូតលាស់ ជាមួយនិងការអនុវត្តន៍បានត្រឹមត្រូវផង ជាពិសេសពុទ្ធសាសនិកជន បំណាងចេញចាកទុក្ខ អំពីការកើតចាស់ឈឺស្លាប់ជាដើម ។ បំណាងនេះ កើតមានតែក្នុងចិត្តគំនិត ជួនកាលរលត់ទៅវិញ ។ បើមានបំណាងហើយក៏ចាប់អនុវត្តធ្វើ ទើបបានសំរេចផល ។ ដូច្នេះត្រូវមានមាតិកាធម៌ទី២ទៀតគឺ វិរិយៈ ។

២- វិរិយៈ ៖ ប្រែថាសេចក្តីព្យាយាម គឺបានអនុវត្តកិច្ចការដែលមានបំណាងហើយ ។ បានសេចក្តីថា ផែនការដែលបានព្រាងទុកក្នុងចិត្តនោះ ឥឡូវនេះបានកើតចេញជាការអនុវត្តន៍ហើយ ។ ដូចជាបំណាងចង់ចេះដឹង ឥឡូវនេះបានកាន់សៀវភៅទៅសិក្សាហើយ ។ សកម្មភាពដែលកំពុងស្តាប់គ្រូពន្យល់ កំពុងសរសេរ កំពុងបំពេញកិច្ចការដែលគ្រូដាក់ឲ្យ កំពុងអានសៀវភៅ សកម្មភាពទាំងអស់នេះហៅថា វិរិយៈ ។ ពុទ្ធបរិស័ទខ្មែរមានបំណាងសំរេចព្រះនិព្វាន ចេញចាកទុក្ខ បានប្រឹងប្រែងប្រតិបត្តិតាមសីលសមាធិបញ្ញា ហៅថា វិរិយៈ ។ ពុទ្ធសាសនិកជនចង់ឲ្យព្រះពុទ្ធសាសនាគង់វង់និងរីកចំរើនលូតលាស់បាននាំគ្នាសិក្សារៀនសូត្រពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយអានសៀវភៅធម៌អាថ៌ ស្តាប់ទេសនា ស្តាប់ឱវាទ សាកសួរគ្នាអំពីធម៌អាថ៌ ។ ពិសេសព្រះសង្ឃគ្រប់វត្តអារាម ចង់ឲ្យយុវជនយុវនារីយល់ដឹងតម្លៃព្រះពុទ្ធសាសនាច្បាស់លាស់ បានបើកបង្រៀនដល់កូនចៅទាំងនោះ នេះហៅថា វិរិយៈ ។ ចង់ឲ្យសេដ្ឋកិច្ចលូតលាស់ចំរើន អ្នកដឹកនាំជាតិបានប្រឹងប្រែងបង្កើនកសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្មឲ្យបានខ្លាំងក្លា ហៅថា វិរិយៈ ។ បើមានតែព្យាយាម ក៏ពុំទាន់គ្រប់គ្រាន់ ដើម្បីសំរេចផលពេញបរិបូណ៌ឡើយ ព្រោះជួនកាល ឈប់ធ្វើវិញ ដោយគ្រាន់តែមានឧបស័គ្គបន្តិចបន្តួច ដូច្នេះត្រូវមានមាតិកាធម៌ទី៣ទៀតគឺ ចិត្តៈ ។

៣- ចិត្តៈ ៖ ប្រែថា ការតាំងចិត្ត ការអធិដ្ឋានចិត្ត ឬការប្តេជ្ញាចិត្ត ។ បានសេចក្តីថា ការតាំងចិត្តដាច់ខាតថា ធ្វើទាល់តែកើតឬទាល់តែសំរេច ទោះបីមានឧបស័គ្គយ៉ាងណាក៏ដោយ ដូចការរៀនសូត្របានតាំងចិត្តថា រៀនទាល់តែចេះ ។ បើដឹកនាំជាតិបានតាំងចិត្តថា បង្រួបបង្រួមជាតិទាល់តែបាន ធ្វើឲ្យសេដ្ឋកិច្ចលូតលាស់ទាល់តែបាន បំបាត់ភាពក្រីក្រនៃប្រជារាស្ត្រទាល់តែបាន ហៅថា ចិត្តៈ ។ បើអ្នកប្រតិបត្តិធម៌ តាំងចិត្តថាព្យាយាមប្រតិបត្តិធម៌ ទាល់តែបានមគ្គផលនិព្វាន បើមិនអាចសំរេចក្នុងបច្ចុប្បន្នជាតិនេះទេ ខ្ញុំសូមប្រាថ្នាជាតិមុខទៀត សូមឲ្យខ្ញុំបានប្រតិបត្តិធម៌នេះតទៅទៀត រហូតបានសំរេចមគ្គផលនិព្វានក្នុងអវសានជាតិ ។ ការតាំងចិត្តដាច់ខាតមិនដាក់ធុរៈចុះ ជួនកាលមិនបានសំរេច ដូច្នេះត្រូវមានមតិកាធម៌ទី៤ទៀតគឺ វិមំសា ។

៤- វិមំសា ៖ ប្រែថាបញ្ញាពិចារណា គឺត្រួតពិនិត្យមើលកិច្ចការដែលបានធ្វើមកហើយ រកហេតុផលដែលនាំឲ្យកិច្ចការដែលបានធ្វើមកហើយមិនបានសំរេច នេះបើកិច្ចការដែលធ្វើនោះមិនបានសំរេច ។ ដើម្បីឲ្យបានជោគជ័យក្នុងកិច្ចការ ត្រូវមានមាតិកាទី៤នេះជាចាំបាច់ ដោយត្រូវត្រួតពិនិត្យមើលជាប់ជានិច្ច នូវកិច្ចការដែលកំពុងប្រព្រឹត្តទៅ ក្រែងការអនុវត្តន៍នោះមិនចំផ្លូវដែលនាំឲ្យសំរេចនូវកិច្ចការនោះ ។ ដូចការសិក្សារៀនរបៀបណាទើបឆាប់ចេះ ទើបប្រឡងជាប់ រកស៊ីរបៀបណាទើបឆាប់បានទ្រព្យសម្បត្តិ ដឹកនាំជាតិបែបណា ទើបឲ្យប្រជាពលរដ្ឋរួបរួមគ្នាបាន ទើបឲ្យសេដ្ឋកិច្ចជាតិលូតលាស់បាន ។ បើពុទ្ធសាសនិកជនវិញ ប្រតិបត្តិធម៌បែបណាទើបឆាប់បានសំរេចមគ្គផលនិព្វាន យើងនេះជាដើម ហៅថា វិមំសា ។ ដូច្នេះយើញថា គ្រប់កិច្ចការទាំងអស់ខាងផ្នែកល្អ ទាំងផ្លូវអាណាចក្រនិងពុទ្ធចក្រ ត្រូវមានឥទ្ធិបាទធម៌ទាំង៤ប្រការនេះ ទើបសំរេចផលពេញលេញបាន ។៚

* *

*